**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកំពង់ឆ្នាំង**

លេខ: ១៦៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការខេត្តកំពង់ឆ្នាំង ជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលខេត្តកំពង់ឆ្នាំង

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ /៩០១ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦ /០៤៣ ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣ /១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិ១ ផលិតផល១ ស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ។
- យោងលិខិតលេខ ០៣២ ភ១.ផ១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ស្តីពីការណែនាំឱ្យរដ្ឋបាលរាជធានី ខេត្ត រៀបចំគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ។
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត ។

## សម្រេច

**ប្រការ ១** :បង្កើតគណៈកម្មាធិការខេត្តកំពង់ឆ្នាំង ជំរុញចលនាភូមិ១ ផលិតផល១ សរសេរអក្សរកាត់ថា ( គ.ខ.ភ១.ផ១)ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឈួរ ចំន្ទឿន** | អភិបាលខេត្ត | ប្រធាន |
| ២- លោក | **ចេង ញ៉ាន់** | អភិបាលរងខេត្ត | អនុប្រធាន |
| ៣- លោក | **ទិន ហ៊ុន** | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៤- លោក | **និត្យ ណារ៉ាន** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ៥- លោក | **ឈួរ ចាន់ថន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៦- លោក | **សេង សារី** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៧- លោក | **អភិបាល** | ក្រុង ស្រុក | សមាជិក |
| ៨- លោក | **អម សុភា** | នាយករដ្ឋបាលសាលាខេត្ត | លេខាធិការ |
| ៩- លោក | **អ៊ុក ឌីម** | នាយកទីចាត់ការអន្តរវិស័យនៃសាលាខេត្ត | ជំនួយការ |

**ប្រការ ២** : គណៈកម្មាធិការខេត្តកំពង់ឆ្នាំងជំរុញចលនាភូមិ១ ផលិតផល១មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១
- ជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ឱ្យទទួលបានជោគជ័យដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។
- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឱ្យទទួលបានជោគជ័យ រួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនតាមសហគមន៍។
- ចូលរួមនិងដឹកនាំការសិក្សា ស្រាវជ្រាវផលិតផល ជាសក្តានុពលនានាដែលមាននៅក្នុងខេត្ត ទាំងផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្ម ដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណា អភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈកាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋានឱ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ។
- សម្របសម្រួលជាមួយអង្គការ -ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញចលនាការអនុវត្តចលនាភូមិ១ ផលិតផល១។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យនិង វាយតម្លៃកម្មវិធី ផែនការសកម្មភាពជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតសមាគម ឬ សហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្តសម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាលផ្សព្វផ្សាយ ប្រមូលផ្តុំ និងដាក់តាំងបង្ហាញ ឬ លក់ផលិតផលភូមិ១ ផលិតផល១។
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជំរុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាពនិងតួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ អង្គភាពពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជំរុញចលនាភូមិ១ ផលិតផល១។

**ប្រការ ៣** : ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ (គ.ខ.ភ១.ផ១) មានដូចខាងក្រោម៖

- គ.ខ.ភ១.ផ១ មានសិទ្ធិរៀបចំបែងចែកភារកិច្ចទទួលខុសត្រូវលម្អិតបន្ថែមទៀតសម្រាប់ជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្តនិង ក្រុង ស្រុក របស់ខ្លួន។
- គ.ខ.ភ១.ផ១ មានលេខាធិការដ្ឋានមួយដឹកនាំដោយនាយករដ្ឋបាល និងមានជំនួយការមួយចំនួនជាមន្ត្រីរដ្ឋបាលរបស់សាលាខេត្តទៅតាមការចាំបាច់ ដោយមានការ ឯកភាពពីគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។

- គ.ខ.ភ១.ផ១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬ សមាគមចូលរួមប្រជុំផ្តល់យោបល់ ឬ ពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១នៅក្នុងខេត្តរបស់ខ្លួន។
- សមាជិក គ.ខ.ភ១.ផ១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬ ករណីពិសេសណាមួយត្រូវស្ថិតក្រោមអធិបតីភាពប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ឬ អនុប្រធានគណៈកម្មាធិការ ដែលត្រូវទទួលបានការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការ។

**ប្រការ ៤** : រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥** : នាយករដ្ឋបាលសាលាខេត្ត សាលាក្រុង សាលាស្រុក មន្ទីរអង្គភាពជុំវិញខេត្តដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ០១ ខាងលើ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

កំពង់ឆ្នាំងថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៤

**អភិបាលខេត្ត**

ឈួរ ច័ន្ទឿន

**ចម្លងជូន**

- *ក្រសួងមហាផ្ទៃ*
- *អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១*
- *ក្រុមប្រឹក្សាខេត្ត*
*(ដើម្បីជូនជ្រាប)*
- *ដូចប្រការ ៥*
- *ឯកសារ កាលប្បវត្តិ*